# របាយការណ៍ប្រចាំឆ្នាំ២០១៨

## ស្តីពី

## ការងារអប់រំផ្សព្វផ្សាយមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ការងារជួយជនពិការដោយសារមីន និងការងារអភិវឌ្ឍន៍ក្រោយបោសសំអាតមីន



នាយកដ្ឋានអប់រំផ្សព្វផ្សាយជួយជនរងគ្រោះដោយសារមីន
និងអភិវឌ្ឍន៍ក្រោយការបោសសម្អាតមីន

ភ្នំពេញ, ខែមករា-ធ្នូឆ្នាំ២០១៨

## A)ផ្នែកអប់រំផ្សព្វផ្សាយជួយជនរងគ្រោះដោយសារមីន

### ក-ស្ថានភាពទូទៅ

ក្នុងឆ្នាំ២០១៨កន្លងមកនេះ ស្ថានភាពរងគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស) បាននៅនឹងថ្កល់គឺជនរងគ្រោះចំនួន៥៨នាក់ ក្នុងមួយឆ្នាំដដែលបើប្រៀបធៀប ទៅនឹងអត្រាគ្រោះថ្នាក់នៃឆ្នាំ២០១៧កន្លងមក ហើយសកម្មភាពដែលបង្កឱ្យមានគ្រោះថ្នាក់កើតឡើងច្រើនតែដោយសារសកម្មភាពកែច្នៃគ្រាប់ ការលេងគ្រាប់ និងការរុករានដី។ល។ ចំណែកគ្រោះថ្នាក់ដោយសារមីនតោនក្នុងឆ្នាំ២០១៨នេះ មានចំនួន៦ករណីហើយបណ្តាលឱ្យមានមនុស្សស្លាប់ និងរបួសកើនដល់៦នាក់លើសពីឆ្នាំ២០១៧ ចំនួន៣នាក់។

តាមប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីនជាតិ(CMVIS)ស្ថានភាពគ្រោះថ្នាក់ដោយសារមីន/ស.ផ.សបានបញ្ជាក់ថារយៈពេល៥ឆ្នាំចុងក្រោយនេះ គឺចាប់ពីឆ្នាំ២០១៤-២០១៨ មានស្រុកចំនួន០៧ដែលមានអត្រាគ្រោះថ្នាក់ខ្ពស់ជាងគេគឺ ស្រុកជាំក្សាន្ត(១៤នាក់)ក្នុងខេត្តព្រះវិហារ, ស្រុកសំឡូត(៦នាក់) សំពៅលូន(៥នាក់) រតនមណ្ឌល(៥នាក់)ក្នុងខេត្តបាត់ដំបង, ស្រុកស្វាយចេក(៦នាក់) ក្នុងខេត្តបន្ទាយមានជ័យ ស្រុកសំរោង(៥នាក់)ក្នុងខេត្តឧត្តរមានជ័យ និងស្រុកមេមត់ ក្នុងខេត្តត្បូងឃ្មុំ។

ការងារអប់រំយល់ដឹងពីគ្រោះថ្នាក់មីន/ស.ផ.ស នៅតែមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ទទួលរងការប៉ះពាល់ដោយសារគ្រាប់មីន/ស.ផ.ស ដូចជានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងព្រំដែនកម្ពុជា-វៀតណាម ក្នុងខេត្តមួយចំនួនដូចជាខេត្តបាត់ដំបងខេត្តបន្ទាយមានជ័យខេត្តឧត្តរមានជ័យខេត្តព្រះវិហារខេត្តត្បូងឃ្មុំ ក្រៅពីនេះ នៅមានខេត្តមួយចំនួនទៀតជុំវិញរាជធានីភ្នំពេញមានដូចជាខេត្តកណ្តាលចំណែកឯទៃទៀតដូចជា ខេត្តកំពង់ឆ្នាំង ខេត្តតាកែវ ខេត្តកំពត ខេត្តកំពង់ស្ពឺ ក្រុងព្រះសីហនុ ខេត្តកោះកុង ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តស្ទឹងត្រែងក៏ត្រូវការអប់រំផ្សព្វផ្សាយយល់ដឹងពីមីន/ស.ផ.សជាចាំបាច់ផងដែរ។

**ទិន្នន័យជនរងគ្រោះថ្នាក់មីន/UXOs ពីឆ្នាំ១៩៩៩-ខែធ្នូឆ្នាំ២០១៨**




## ខ-ស្ថានភាពបុគ្គលិក

កម្មវិធីអប់រំការយល់ដឹងពីមីន និងគ្រាប់មិនទាន់ផ្ទុះ មានបុគ្គលិកសរុបចំនួន៣៤នាក់ ដែលនឹងកំពុងតែពង្រឹង/ពង្រីកសមត្ថភាពដល់គណៈកម្មាធិការមីនស្ម័គ្រចិត្ត/គ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តនិងមេភូមិនាយប៉ុស្តិ៍នគរបាលទូទាំងប្រទេសចំនួន១,១០៣នាក់ដែលពួកគាត់កំពុងតែបំពេញប្រតិបត្តិការនៅក្នុងតំបន់ទទួលរងនូវការគំរាមកំហែងពីមីន/គ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះនានា មានដូចខាងក្រោម៖

### *ក/បុគ្គលិក:*

| | |
|---|---|
| ១-ប្រធាននាយកដ្ឋាន | ០១ នាក់ |
| ២-អនុប្រធាននាយកដ្ឋាន | ០១ នាក់ |
| ៣-ប្រធានការិ.អប់រំផ្សព្វផ្សាយមីន និងជួយជនពិការដោយសារមីន | ០១ នាក់ |
| ៤-ទីប្រឹក្សានាយកដ្ឋានអប់រំផ្សព្វផ្សាយមីន | ០១ នាក់ |
| ៥-នាយសម្របសម្រួលការងារមីន/គ្រាប់ប្រចាំខេត្ត | ០៦ នាក់ |
| ៦-នាយតំណាងមីនប្រចាំស្រុកCBMRR-DFP | ១៧នាក់ |
| ៧-នាយតំណាងគ្រាប់មិនទាន់ផ្ទុះប្រចាំស្រុក/ខេត្តCBMRR-DFP | ០៧នាក់ |

**សរុបរួម:៣៤នាក់**

ចំពោះបុគ្គលិកអប់រំមីនមានការថយចុះ ពីខែមិថុនា ឆ្នាំ២០១៥ មកដល់ខែធ្នូ ឆ្នាំ២០១៧នៅត្រឹមតែ២៣នាក់ប៉ុណ្ណោះ ដោយសារដាច់គម្រោងមួយចំនួន។ ចាប់ពីខែមីនា ឆ្នាំ២០១៨រហូតមកដល់បច្ចុប្បន្ននេះ បុគ្គលិកយើងកើនឡើងដល់ចំនួន៣៤នាក់ ដោយសារគម្រោង (USA-CCL-APOPO) គាំទ្រឱ្យដំណើរការឡើងវិញ។ ចំពោះស្ថានភាពបុគ្គលិកពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨ មានបង្ហាញលម្អិតដូចក្នុងតារាងលេខ១ ខាងក្រោមនេះ៖

| ក្រុម ប្រតិបត្តិការ | ចំនួនបុគ្គលិក | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 6-2011 | 12-2011 | 12-2012 | 6-2013 | 12-2013 | 6-2014 | 12-2014 | 6-2015 | 12-2015 | 12-2016 | 12-2017 | 06-2018 |
| Director MRE& VA/PCD | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| Dep.Director MRE/VA/PCD | | | | | | 1 | 1 | 1 | 1 | 1 | 1 | 1 |
| Chief Of MRE | | | | | | | | | | 1 | 1 | 1 |
| TA MRE | | | | | | | | | | | | 1 |
| MRE Officer | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 0 | 0 | 0 |
| CBMRR-TMO | 1 | 1 | 1 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| CBMRR-PC | 2 | 3 | 4 | 4 | 4 | 4 | 4 | 4 | 4 | 3 | 3 | 6 |
| MRER Team | 13 | 4 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| CBMRR-DFP | 17 | 20 | 23 | 24 | 24 | 24 | 24 | 17 | 17 | 17 | 17 | 17 |
| CBURR-DFP | 19 | 18 | 18 | 18 | 18 | 18 | 0 | 0 | 0 | 0 | 0 | 7 |
| **សរុប** | **51** | **48** | **48** | **49** | **48** | **49** | **31** | **24** | **24** | **23** | **23** | **34** |

**តារាងលេខ១៖ស្ថានភាពបុគ្គលិកអប់រំមីនពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨**

### *ខ/អ្នកស្ម័គ្រចិត្ត:*

១-កម្មវិធីកាត់បន្ថយគ្រាប់មីនតាមសហគមន៍(CBMRR)

១- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ទាំង០៣កម្រិត ៦៤១នាក់

២- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ទើបបង្កើតថ្មី ១៥០នាក់

សរុបៈ៧៩១នាក់កំពុងដំណើរការ

៣- គណៈកម្មាធិការមីនស្ម័គ្រចិត្ត CBMRR ចាកចេញពីកម្មវិធី(Phase Out):២២៧នាក់

**សរុបទាំងកំពុងដំណើរការនិងចាកចេញពីកម្មវិធីចំនួន១,០១៨នាក់**

២-កម្មវិធីកាត់បន្ថយគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះតាមសហគមន៍(CBURR)

១-បណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តជាមេភូមិ ឃុំ ស្រុក ៥៦០នាក់

២-បណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តជាមន្ត្រីនគរបាលជាតិ ៣៣០នាក់

៣-បុគ្គលិកស៊ីម៉ាក់បំរើការងារតាមទីវាល ៩៧២នាក់

សរុបៈ១,៨៦២នាក់ កំពុងដំណើរការ

៤-បណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តCBURRចាកចេញពីកម្មវិធីចំនួន ១២៨នាក់

**សរុបទាំងកំពុងដំណើរការនិងចាកចេញពីកម្មវិធីចំនួន ១,៩៩០នាក់**

**សរុបរួមទាំង២កម្មវិធី (CBMRR-CBURR) អ្នកស្ម័គ្រចិត្តបង្កើតបានចំនួនៈ៣,០០៨នាក់**

រូបភាពកម្មវិធី(CBMRR)





រូបភាពកម្មវិធី(CBURR)



## គ-ការពង្រាយកម្លាំង

## ១-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍

Community Based Mine Risk Reduction(CBMRR)

បច្ចុប្បន្ននេះមានបុគ្គលិកនាយតំណាងមីនប្រចាំស្រុក(DFP)ម្នាក់ នៅតាមស្រុកគោលដៅទាំង២៤ កំពុងដំណើរការរាល់ថ្ងៃចំនួន ១៧នាក់ ចប់គម្រោងចំនួន ៧នាក់។ ពួកគេមានសមាសភាពជ្រើសចេញមកពីមន្ត្រីជំនាញជុំវិញសាលាស្រុក ជួយធ្វើការសម្របសម្រួល លើសេវាកម្មទាំងបី មានសេវាកម្មមីន សេវាកម្មអភិវឌ្ឍន៍ និងសេវាកម្មជនពិការ។ ក្នុងការពង្រឹង/ពង្រីកសមត្ថភាពដល់បណ្តាញមីនស្ម័គ្រចិត្ត

ទាំង៧៩១នាក់ នៅកម្រិតភូមិ-ឃុំ ស្រុក មានសមាសភាពជាមេភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រីជំនាញជុំវិញសាលាស្រុក ដើម្បីឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចេះប្រមូលយកព័ត៌មាន តាមបែបចូលរួម (PLA) វិភាគបញ្ហា/កំណត់តម្រូវការភូមិ តាមរយៈចំណាត់អាទិភាពតម្រូវការ ហើយយកតម្រូវការទាំងនេះទៅរៀបចំជាផែនការសកម្មភាពរបស់ភូមិ ដើម្បីងាយស្រួលតាមដាន បញ្ចូលផែនការវិនិយោគឃុំ/សង្កាត់ ពិសេសផែនការបោសសម្អាតមីន ព្រមទាំងជួយអប់រំផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពមីន/ស.ផ.ស បន្តដល់សហគមន៍មូលដ្ឋានរបស់ពួកគេជាប្រចាំ លើភូមិគោលដៅចំនួន២៨៤ភូមិ ឃុំគោលដៅចំនួន៩៦ឃុំ ក្នុង២៦ស្រុកគោលដៅ ក្នុងខេត្តទាំង៦មាន៖

- ខេត្តពោធិ៍សាត់មាន២ស្រុកគឺៈ ភ្នំក្រវាញ និងស្រុកវាលវែង។
- ខេត្តបាត់ដំបងមាន១០ស្រុកគឺៈ ស្រុកមោងឫស្សី ស្រុករុក្ខគិរី ស្រុកគាស់ក្រឡ ស្រុកបាណន់ ស្រុករតនមណ្ឌល ស្រុកសំឡូត ស្រុកបវេល ស្រុកកំរៀង ស្រុកភ្នំព្រឹកនិងស្រុកសំពៅលូន។
- ខេត្តប៉ៃលិនមាន២ស្រុកគឺៈ ក្រុងប៉ៃលិន និងខណ្ឌសាលាក្រៅ។
- ខេត្តបន្ទាយមានជ័យមាន៥ស្រុកគឺៈ ស្រុកម៉ាឡៃ ស្រុកអូរជ្រៅ ក្រុងប៉ោយប៉ែត ស្រុកស្វាយចេក និងស្រុកថ្មពួក។
- ខេត្តឧត្តរមានជ័យ៣ស្រុកគឺៈ ស្រុកបន្ទាយអំពិល ស្រុកសំរោង ស្រុកត្រពាំងប្រាសាទ (បុគ្គលិក DFPទាំង៣នេះ បានចប់គម្រោងតាំងក្នុងខែមេសា ឆ្នាំ២០១៥)។
- ខេត្តព្រះវិហារមាន៤ស្រុកគឺៈ ស្រុកគូលែន ស្រុកជាំក្សាន្ត ស្រុកត្បែងមានជ័យ និងស្រុកឆែប (បុគ្គលិកDFPទាំង៤នេះ បានចប់គម្រោងតាំងពីខែធ្នូ ឆ្នាំ២០១៤)។

## ២-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍

Community Based UXO Risk Reduction(CBURR)

កម្មវិធីនេះយើងពង្រីកបាន៦១ស្រុក ឋិតក្នុង១៧ខេត្តគោលដៅ ដែលយើងបានធ្វើការសាកល្បងរកគន្លឹះគ្រប់គ្រង និងបង្កើនការងារអប់រំផ្សព្វផ្សាយយល់ដឹងពីមីន ឱ្យបានទូលំទូលាយជាសាធារណៈ ក្នុងសហគមន៍មូលដ្ឋានឱ្យកាន់តែមាននិរន្តរភាព និងប្រសិទ្ធភាពខ្ពស់ ដោយចែកការងារចេញជា០៤ដំណាក់កាលដូចខាងក្រោម៖

### ២.១-ដំណាក់កាលទី១

កម្មវិធីបង្កើតឱ្យមានបុគ្គលិក នាយតំណាងគ្រាប់មិនទាន់ផ្ទុះប្រចាំស្រុក (CBURR-DFP) ម្នាក់នៅតាមស្រុកគោលដៅទាំង១៨ ដែលមានសមាសភាព ជ្រើសចេញមកពីមន្ត្រីនគរបាលស្រុក ជួយធ្វើការសម្របសម្រួលលើសេវាកម្មមីន ក្នុងការបង្ហាញពីទីតាំងមីន/គ្រាប់មិនទាន់ផ្ទុះ សេសសល់ពីសង្គ្រាម និងធ្វើការអប់រំផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពមីន/ស.ផ.ស ដល់ប្រជាពលរដ្ឋទូទៅក្នុងស្រុករបស់ខ្លួន តាមរយៈការប្រមូលព័ត៌មានពីបញ្ហាមីន/ស.ផ.ស ជូនមកប្រតិបត្តិករបោសសម្អាតមីន/ស.ផ.ស ដើម្បីធ្វើការកម្ទេចចោលចំនួន៤ខេត្តរួមមានៈ

- ខេត្តកំពង់ឆ្នាំងមានចំនួន៦ស្រុកគឺៈ ស្រុករលាប្អៀរ ស្រុកសាមគ្គីមានជ័យ ស្រុកទឹកផុស ក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច និងស្រុកបរិបូណ៌។
- ខេត្តកំពង់ធំមានចំនួន៣ស្រុកគឺៈ ស្រុកស្ទោង ស្រុកស្ទឹងសែន និងស្រុកបារាយណ៍។
- ខេត្តពោធិ៍សាត់មានចំនួន៣ស្រុកគឺៈ ក្រុងពោធិ៍សាត់ ស្រុកបាកាន និងស្រុកក្រគរ។
- ខេត្តសៀមរាបមានចំនួន៦ស្រុកគឺៈ ស្រុកជីក្រែង ស្រុកស្វាយលើ ស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី ស្រុកអង្គរធំ និងស្រុកប្រាសាទបាគង ប៉ុន្តែគម្រោងខាងលើនេះត្រូវបានបញ្ចប់ក្នុងខែតុលាឆ្នាំ២០១៤កន្លងមកនេះ។

## ២.២-ដំណាក់កាលទី២

បង្កើតឱ្យមានជាបណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តប្រចាំភូមិម្នាក់និងឃុំម្នាក់នៅតាមស្រុកគោលដៅទាំង២៧ដោយពុំចាំបាច់ចំណាយថវិកាសម្រាប់បង្កើតបុគ្គលិកទេក្នុងគោលបំណងពង្រីកបណ្តាញស្ម័គ្រចិត្តឱ្យបានច្រើនជាអតិបរិមាធ្វើឱ្យការផ្សព្វផ្សាយព័ត៌មានសុវត្ថិភាពបន្តទៅក្នុងសហគមន៍មូលដ្ឋានបានទូលំទូលាយជាសាធារណៈនិងការផ្តល់ព័ត៌មានគ្រាប់មិនទាន់ផ្ទុះត្រឡប់មកវិញតាមរយៈការយល់ដឹងរបស់ពួកគេជាបន្តបន្ទាប់(របៀបភ្នែកម្នាស់) ជូនមកប្រតិបត្តិករបោសសម្អាតមីន/ស.ផ.សដើម្បីធ្វើការកម្ទេចចោល។ សមាសភាពជ្រើសថ្នាក់មេភូមិជាបណ្តាញស្ម័គ្រចិត្តភូមិនាយប៉ុស្ដិ៍នគរបាលឃុំ/សង្កាត់ជាបណ្តាញស្ម័គ្រចិត្តឃុំដែលមានចំនួន៤៦២នាក់បិតនៅក្នុងភូមិគោលដៅចំនួន៣០៩ភូមិឃុំចំនួន១៥៨ឃុំលើស្រុកចំនួន២៧នៃទូទាំងចំនួន ០៥ខេត្តរួមមានៈ

- ខេត្តកំពង់ចាមមានចំនួន៦ស្រុកគឺៈស្រុកបាធាយស្រុកជើងព្រៃស្រុកព្រៃឈរស្រុកចំការលើស្រុកកំពង់សៀមស្រុកស្ទឹងត្រង់។
- ខេត្តត្បូងឃ្មុំមានចំនួន៦ស្រុក-ក្រុង គឺៈក្រុងសួង ស្រុកត្បូងឃ្មុំនិងស្រុកពញាក្រែកស្រុកតំបែរស្រុកមេមត់និងស្រុកអូររាំងឪ។
- ខេត្តក្រចេះមានចំនួ៥ស្រុកគឺៈស្រុកស្នួលស្រុកចិត្របុរីស្រុកសម្បូរស្រុកព្រែកប្រសប់និងស្រុកឆ្លូង។
- ខេត្តស្វាយរៀងមានចំនួន៧ស្រុកគឺៈស្រុកស្វាយរៀងស្រុកចន្ទ្រាស្រុករមាសហែកស្រុកស្វាយទាបស្រុករំដួលស្រុកស្វាយជ្រុំនិងស្រុកកំពង់រោទ៍។
- ខេត្តព្រៃវែងមានចំនួន៤ស្រុកគឺៈស្រុកកំចាយមារស្រុកព្រះស្តេចស្រុកបាភ្នំនិងស្រុកកំពង់ត្របែក។

## ២.៣-ដំណាក់កាលទី៣

ថ្មីៗនេះនៅក្នុងឆ្នាំ២០១៧យើងបានបង្កើតឱ្យមានជាបណ្តាញគ្រាប់មិនទាន់ផ្ទុះស្ម័គ្រចិត្តប្រចាំភូមិម្នាក់ជាមេភូមិនិងមន្ត្រីនគរបាលនៅតាមស្រុកគោលដៅទាំង៣២ឃុំ៧៩ និងភូមិ៨២ដែលមានមនុស្សសរុបចំនួន៣២០នាក់នៅក្នុងខេត្តចំនួន៦គឺៈមានខេត្តស្វាយរៀង, ខេត្តព្រៃវែង, ខេត្តកំពង់ធំ, ខេត្តសៀមរាបខេត្តឧត្តរមានជ័យនិងខេត្តព្រះវិហារក្នុងនោះយើងបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងកិច្ចការប៉ុស្ដិ៍របស់ស្នងការនគរបាលខេត្តទាំង៦ដោយសហការជាមួយប្រធានការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍នៃស្នងការនគរបាលខេត្តតាមការបណ្តុះបណ្តាលជំនាញអប់រំផ្សព្វផ្សាយយល់ដឹងពីមីន និងជំនាញអភិវឌ្ឍសហគមន៍ទៅពួកគាត់ធ្វើជាគ្រូ

បង្គោលសម្រាប់បណ្តុះបណ្តាលជំនាញអប់រំនេះបន្តដល់គ្រប់នាយប៉ុស្តិ៍នគរបាលទូទាំងខេត្តរបស់ខ្លួន។នេះជាការបញ្ជ្រាបជំនាញអប់រំផ្សព្វផ្សាយមីនដោយភ្ជាប់ជាមួយភារកិច្ចរបស់ពួកគាត់***ក្នុងចំណុចទី៧ស្តីពីការងារអប់រំមីន/ស.ផ.សក្នុងគោលនយោបាយ (ភូមិ-ឃុំមានសុវត្ថិភាព)***។ ព្រមជាមួយនេះដែរយើងក៏បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងលទ្ធផលអប់រំផ្សព្វផ្សាយមីន/ស.ផ.សគ្រប់បណ្តាប៉ុស្តិ៍ទូទាំងខេត្តដោយពួកគាត់ជាប្រធានការិយាល័យគ្រប់គ្រងកិច្ចការប៉ុស្តិ៍ធ្វើការបូកសរុបនិងផ្តល់របាយការណ៍ខែប្រចាំខែមកកាន់ទីបញ្ជាការភ្នំពេញតាមរយៈនាយសម្របសម្រួលការងារគ្រាប់មិនទាន់ផ្ទុះប្រចាំខេត្ត(PC) សហការជាមួយនាយផ្នែកទិន្នន័យតាមកងឯកភាពកំចាត់មីនទី៦, ៥និងទី៤ក្នុងការបញ្ចូលទិន្នន័យជាផ្លូវការ។ ដោយយើងគ្រាន់តែបើកវគ្គបណ្តុះបណ្តាលផ្តល់ជំនាញគ្រូបង្គោលនិងថវិកាលើកទឹកចិត្តជាCellCard ប្រចាំខែដល់ពួកគាត់តែប៉ុណ្ណោះខាងក្រោមនេះជាចំនួនមន្ត្រីស្ម័គ្រចិត្ត៖

- ខេត្តស្វាយរៀងមានចំនួន២ស្រុកគឺៈស្រុករមាសហែកនិងស្រុកស្វាយជ្រុំចំនួន៣២នាក់ក្នុងនោះមាន( មេភូមិ១០នាក់មន្ត្រីម៉ាពូ១នាក់និងមន្ត្រីនគរបាល២១នាក់ )
- ខេត្តព្រៃវែងមានចំនួន៤ស្រុកគឺៈស្រុកពារាំងស្រុកពាម(រ)ស្រុកស្វាយអន្ទរនិងស្រុកពោធិ៍រៀងចំនួន២៨នាក់( មេភូមិ១៣នាក់មន្ត្រីម៉ាពូ១នាក់និងមន្ត្រីនគរបាល១៤នាក់ )
- ខេត្តកំពង់ធំមានចំនួន៦ស្រុកគឺៈស្រុកកំពង់ស្វាយស្រុកប្រាសាទបល្ល័ង្កស្រុកប្រាសាទសំបូរស្រុកសណ្តាន់ស្រុកសន្ទុកនិងស្រុកបារាយណ៍ចំនួន២៣នាក់( មន្ត្រីនគរបាល២២នាក់និងមន្ត្រីម៉ាពូ១នាក់ )
- ខេត្តសៀមរាបមានចំនួន៧ស្រុកគឺៈស្រុកអង្គរធំស្រុកបន្ទាយស្រីស្រុកជីក្រែងស្រុកវ៉ារិនប្រាសាទបាគងសូទ្រនិគមនិងស្រុកស្វាយលើចំនួន២៧នាក់( មន្ត្រីនគរបាល២៦នាក់និងមន្ត្រីម៉ាពូ១នាក់ )
- ខេត្តឧត្តរមានជ័យមានចំនួន៥ស្រុកគឺៈស្រុកបន្ទាយអំពិលស្រុកចុងកាល់ស្រុកសំរោងស្រុកអន្លង់វែងនិងស្រុកត្រពាំងប្រាសាទចំនួន២៤នាក់( មន្ត្រីនគរបាល២៣នាក់និងមន្ត្រីម៉ាពូ១នាក់ )
- ខេត្តព្រះវិហារមានចំនួន៨ស្រុកគឺៈក្រុងព្រះវិហារស្រុកត្បែងមានជ័យស្រុកសង្គមថ្មីស្រុករវៀងស្រុកគូលែនស្រុកជ័យសែនស្រុកស្រុកឆែបនិងស្រុកជាំក្សាន្តចំនួន១៨៧នាក់( មេភូមិ១៦០នាក់មន្ត្រីនគរបាល២៦នាក់និងមន្ត្រីម៉ាពូ១នាក់ )។

## ៣-ក្រុមអប់រំផ្សេងៗរបស់ស៊ីម៉ាក់:

ក្រៅពីក្រុមអប់រំខាងលើការអប់រំយល់ដឹងពីមីន/គ្រាប់មិនទាន់ផ្ទុះក៏បានអនុវត្តនៅតាមក្រុមប្រតិបត្តិការផ្សេងៗដូចជាក្រុម EOD, BAC, BAC-L, BAC-MTT, BAC-S, BC, DM, ERWI, LLD, BLS, CRWS, DIV, ECS, EDO, MDR, NTS, OPS DU, SLD, TSC and Platoonដែលកំពុងបំពេញប្រតិបត្តិការនៅតាមកងឯកភាពកំចាត់មីននានា និងក្រុមស្ថិតនៅក្រោមចំណុះទីបញ្ជាការភ្នំពេញ។

## គ-លទ្ធផលសម្រេចបាន

## ១-លទ្ធផលការងារអប់រំការយល់ដឹងពីមីន/ស.ផ.សតាមក្រុម

១.១-ការអប់រំរបស់គណៈកម្មាធិការមីនស្ម័គ្រចិត្តកម្មវិធី CBMRR&CBURR និងក្រុមចល័តនានាក្នុងឆ្នាំ២០១៨នេះ មាន១៦៥ក្រុម បានធ្វើការអប់រំយល់ដឹងពីមីន ដែលទទួលបានលទ្ធផលដូចមានលម្អិតជូននៅក្នុងតារាងលេខ២ ខាងក្រោមនេះ៖

| ក្រុម | ចំនួនក្រុម | ចំនួនមនុស្សដែលទទួលបានការអប់រំ | | | | | | ចំនួនខ្នងផ្ទះ |
|---|---|---|---|---|---|---|---|---|
| | | លើក | បុរស | ស្ត្រី | កុមារក្នុងប្រព័ន្ធ | កុមារក្រៅប្រព័ន្ធ | សរុប | |
| | 1 | 5 | 1,047 | 901 | 702 | 58 | 2,708 | |
| BAC | 4 | 28 | 116 | 162 | 8 | 49 | 335 | 4 |
| BAC-L | 5 | 55 | 369 | 316 | 4 | 79 | 768 | 1 |
| BAC-MTT | 6 | 721 | 3,363 | 2,326 | 864 | 3,555 | 10,108 | 212 |
| BAC-S | 14 | 1,078 | 5,930 | 5,062 | 1,281 | 3,207 | 15,480 | |
| BC | 12 | 144 | 735 | 567 | 19 | 49 | 1,370 | 73 |
| BLS | 1 | 6 | 120 | 118 | 112 | 81 | 431 | 160 |
| CBMRR | 21 | 6,417 | 42,975 | 47,041 | 25,751 | 11,518 | 127,285 | 7,267 |
| CBURR | 21 | 1,546 | 145,098 | 158,485 | 95,864 | 33,012 | 432,459 | 99,581 |
| CRWS | 3 | 150 | 482 | 296 | | 1 | 779 | 69 |
| DIV | 2 | 31 | 145 | 82 | | 72 | 299 | 35 |
| DM | 9 | 108 | 395 | 254 | 44 | 23 | 716 | |
| ECS | 3 | 102 | 622 | 364 | 40 | 139 | 1,165 | 37 |
| EDD | 4 | 191 | 447 | 385 | 165 | 329 | 1,326 | 10 |
| EOD | 3 | 241 | 7,685 | 7,485 | 2,143 | 2,215 | 19,528 | 370 |
| ERWI | 7 | 264 | 1,266 | 1,002 | 5,477 | 1,105 | 8,850 | 56 |
| LLD | 1 | 1 | 5 | 6 | | 11 | 22 | |
| MDR | 1 | 14 | 201 | 91 | 5 | 14 | 311 | |
| NTS | 3 | 94 | 1,492 | 1,075 | 622 | 586 | 3,775 | 551 |
| OPS DU | 1 | 135 | 410 | 388 | 81 | 638 | 1,517 | |
| OPS Officer | 1 | 5 | 27 | | | | 27 | |
| Platoon | 10 | 142 | 640 | 514 | 69 | 208 | 1,431 | 37 |
| SLD | 6 | 77 | 441 | 425 | 63 | 213 | 1,142 | 21 |
| TSC | 26 | 424 | 12,631 | 13,131 | 3,000 | 1,330 | 30,092 | 128 |
| **Grand Total:** | **165** | **11,979** | **226,642** | **240,476** | **136,314** | **58,492** | **661,724** | **108,612** |

តារាងលេខ២៖ លទ្ធផលអប់រំយល់ដឹងពីមីនក្នុងឆ្នាំ២០១៨

១.២-ការអប់រំរបស់នាយតំណាងមីនប្រចាំស្រុកទាំង១៧CBMRR–DFP ដល់អ្នកប្រើប្រាស់គ្រឿងចក្រគ្រប់ប្រភេទក្នុងតំបន់សង្ស័យមានមីនតោន:

ឆ្នាំ២០១៨នេះនាយតំណាងមីនប្រចាំស្រុក(DFP)កម្មវិធី CBMRR បានចុះធ្វើការអប់រំដោយផ្ទាល់ដល់អ្នកប្រើប្រាស់គ្រឿងចក្រនានា នៅក្នុងតំបន់ដែលមានមីនតោន អ្នករុករានដីកសិកម្មនៅក្នុងតំបន់ដែលមិនទាន់មានការបោសសម្អាតមីន ធ្វើបច្ចុប្បន្នភាពមីនតោនលើផែនទីភូមិ និងអប់រំអ្នកមានចរឹតចចេសរឹងរូសទទួលបាននូវលទ្ធផលដូចខាងក្រោម៖

| តំបន់គោលដៅ | ម្ចាស់គ្រឿងចក្រ | អ្នកក្រីក្រប្រឈមនឹងគ្រោះថ្នាក់មីន | អ្នកពង្រីកដីកសិកម្មក្នុងតំបន់មីន | ជនចចេសរឹងរូស | ធ្វើបច្ចុប្បន្នភាពផែនទីនូវព័ត៌មានមីនតោន | លទ្ធផលសំរេចបានជា% |
|---|---|---|---|---|---|---|
| DU1-BMC | 1,200 | 1050 | 854 | 51 | 9 | 108% |
| DU2-BTB | 2,014 | 1,560 | 1159 | 84 | 13 | 94% |
| DU2-PLN | 2,010 | 1520 | 1087 | 76 | 13 | 107% |

| | | | | | | |
|---|---|---|---|---|---|---|
| Total | 5,224 | 4,130 | 3,100 | 211 | 35 | 102.88% |

តារាងលេខ៣៖ លទ្ធផលអប់រំយល់ដឹងពីមីនតោនឆ្នាំ២០១៨









បញ្ជាក់:

លទ្ធផលសរុបទទួលបាន **102.88%**នៃសន្ទស្សន៍ផែនការ ប្រចាំឆ្នាំ២០១៨ ដោយបុគ្គលិក DFPយើងមានឆន្ទៈមុះមុត ក្នុងការងារទើបសម្រេចបាន នូវលទ្ធផលគួរជាទីគាប់ចិត្ត។

## ២-ការរាយការណ៍ពីមីន/គ្រាប់មិនទាន់ផ្ទុះ និងការប្រើប្រាស់សម្ភារៈ

ឆ្នាំ២០១៨ចាប់ពីខែមករា រហូតដល់ខែតុលា(រយៈពេល១០ខែ)ក្រុមអប់រំការយល់ដឹងពីគ្រោះថ្នាក់មីននិងគ្រាប់មិនទាន់ផ្ទុះទាំងអស់ទទួលបានសំណើកម្ទេចមីននិងគ្រាប់មិនទាន់ផ្ទុះសរុបចំនួន២,២៣៣ សំណើ និងបានសម្របសម្រួល និងឆ្លើយតបបានចំនួន២,១៥៣សំណើ។ ចំពោះលទ្ធផលលម្អិត តាមក្រុម និងការប្រើប្រាស់សម្ភារៈអប់រំមានក្នុង **តារាងលេខ៤** និង**តារាងលេខ៥**

| Demining Tools | Mine/UXO Reported | | | | | Mine/UXO Responded | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | Number of Repuest | AP | AT | UXO | Caliber (kg) | Number of Repuest | AP | AT | UXO | Caliber (kg) |
| | | | | 4 | | | | | 4 | |
| BAC | 1 | 3 | | 2 | | 1 | 3 | | 2 | |
| BAC-L | 3 | | | 4 | 2 | 2 | | | 7 | 2 |
| BAC-MTT | 794 | | | 3,240 | 1 | 818 | | | 3,469 | |
| BAC-S | 25 | | | 270 | | 25 | | | 270 | |
| BC | 14 | 6 | | 12 | | 11 | 2 | | 10 | |
| BLS | | | | | | | | | | |
| CBMRR | 768 | 768 | 25 | 2,231 | 47 | 687 | 713 | 18 | 2,135 | 45 |
| CBURR | 140 | 11 | | 716 | 86 | 137 | 14 | | 613 | 86 |
| CRWS | | | | | | | | | | |
| DIV | 22 | | | 23 | | 15 | | | 15 | |
| DM | 4 | 22 | | 18 | | 3 | 4 | | 2 | |
| ECS | 6 | 2 | 2 | 56 | | 5 | 2 | 2 | 45 | |
| EDD | | | | | | | | | | |
| EOD | 289 | 76 | | 1,403 | | 289 | 76 | | 1,393 | |
| ERWI | 337 | 368 | 9 | 1,185 | 42 | 325 | 364 | 9 | 1,130 | 42 |
| LLD | | | | | | | | | | |
| MDR | | | | | | | | | | |
| NTS | | | | 1 | | | | | | |
| OPS DU | 183 | 38 | 3 | 2,136 | 42 | 183 | 38 | 3 | 2,136 | 42 |
| OPS Officer | | | | | | | | | | |
| Platoon | 3 | | | 3 | | 2 | | | 2 | |
| SLD | 2 | | | 2 | | 1 | 1 | | 2 | |
| TSC | 38 | 25 | 4 | 90 | 2 | 33 | 20 | 4 | 81 | |
| **Grand Total:** | **2,629** | **1,319** | **43** | **11,396** | **222** | **2,537** | **1,237** | **36** | **11,316** | **217** |

តារាងលេខ៤៖ ការទទួលរបាយការណ៍គ្រាប់ និងការឆ្លើយតប

| Demining Tools | MRE Material Used | | | | | | | |
|---|---|---|---|---|---|---|---|---|
| | Big T-Shirt | Smal T-Shirt | Note Book | Poster | Flyer | Leaflet | VCD | Others |
| Asst.OPS | | | | 50 | | | | |
| BAC | | | | 20 | | | | |
| BAC-L | 10 | | | 13 | 16 | | | |
| BAC-MTT | | | | 60 | | | | |
| BAC-S | | | | 153 | 363 | | | |
| BC | | | 3 | 14 | 8 | 2 | | |
| BLS | | | 300 | 100 | | | | |
| CBMRR | 800 | 550 | 4,521 | 780 | 61 | 5,500 | | |
| CBURR | 1,200 | 300 | 3,028 | 1,230 | | 3,000 | | |
| CRWS | | | 100 | 50 | 68 | 100 | | |
| DIV | | | | 10 | | | | |
| DM | | | 3 | 12 | 14 | 13 | | |
| ECS | | | | 4 | | | | |
| EDD | | | 39 | 450 | 38 | 100 | | |
| EOD | | | 100 | 500 | | 100 | | |
| ERWI | | | 88 | 40 | | 100 | | 2 |
| LLD | | | | 30 | | | | |
| MDR | | | | 17 | 14 | 50 | | |
| NTS | | | | 20 | | | | |
| OPS DU | | | 100 | 100 | | 200 | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Platoon | | 2 | 100 | 500 | 11 | 450 | | |
| SLD | | | 50 | 50 | | 50 | | |
| TSC | 6 | 6 | 18 | 50 | 21 | 50 | | 1 |
| **Grand Total:** | **2,016** | **858** | **8,450** | **4,253** | **614** | **9,715** | | **3** |

តារាងលេខ៥៖ ការប្រើប្រាស់សម្ភារៈអប់រំ

## ៣-សកម្មភាពការងារៈ

៣.១- ថ្ងៃទី១៩-២៣ខែកុម្ភៈឆ្នាំ២០១៨បុគ្គលិកMRE គ្រប់កងឯកភាពកំចាត់មីនបណ្តាញមីន/គ្រាប់ស្ម័គ្រចិត្តនិងមន្ត្រីនគរបាលស្ម័គ្រចិត្តទាំងអស់បានបើកយុទ្ធនាការរយៈពេល( ០៤ថ្ងៃ )ចុះធ្វើសកម្មភាពអប់រំផ្សព្វផ្សាយយល់ដឹងពីព័ត៌មានសុវត្ថិភាពគ្រាប់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាមដល់ប្រជាពលរដ្ឋគ្រប់ខេត្ត/ក្រុងដើម្បីចូលរួមអបអរសាទរទិវាយល់ដឹងពីមីន២៤កុម្ភៈខួបលើកទី១៩បានចំនួន៦៤,៣៨៨នាក់។





៣.២- ថ្ងៃទី២២ខែកុម្ភៈឆ្នាំ២០១៨ចូលរួមអង្គមីទិញទិវាយល់ដឹងពីមីន២៤កុម្ភៈលើកខួបទី១៩នៅទីរួមខេត្តឧត្តរមានជ័យរៀបចំដោយអាជ្ញាធរមីនកម្ពុជា។





៣.៣- ថ្ងៃទី០៦ខែមិនាឆ្នាំ២០១៨ចុះជ្រើសរើសបុគ្គលិកនាយតំណាងគ្រាប់មិនទាន់ផ្ទុះ ក្នុងគម្រោង JMAS សហការពិភាក្សាជាមួយលោកស្នងការខេត្តកំពង់ធំនិងអធិការស្រុកកំពង់ស្វាយបានយល់ព្រមអនុ

ញ្ញាតិឱ្យឈ្មោះគង់តាំងស័រភេទស្រីអាយុ៣០ឆ្នាំមានឋានៈជានាយរងផ្នែកនគរបាលយុត្តិធម៌ធ្វើជាDFP ប្រចាំស្រុកកំពង់ស្វាយ។




៣.៤- ថ្ងៃទី២០ខែមិនាឆ្នាំ២០១៨បើកវគ្គបណ្តុះបណ្តាលDFPថ្មីDU#4 ស្រុកកំពង់ស្វាយ គម្រោងJMAS ស្តីពីការលើកកម្ពស់តួនាទី-ភារកិច្ចនិងការយល់ដឹងពីមីនព្រមទាំងជំនាញសម្របសម្រួលទំនាក់ទំនងសហគមន៍ក្នុងនោះមាន Data base Officer and Senoir OPS ចូលរួមរយៈពេល២ថ្ងៃ ទីតាំងក្នុងសាលប្រជុំអធិការស្រុកកំពង់ស្វាយខេត្តកំពង់ធំ។




៣.៥- ថ្ងៃទី១១-១៥ខែមិថុនាឆ្នាំ២០១៨ចុះជ្រើសរើស PC នៅDU#5 ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តស្ទឹងត្រែង និងPC DU#6, DU#4 ថ្មី និងDFP ស្រុកឆែប ស្រុកត្រពាំងប្រាសាទ ស្រុកអន្លង់វែង និងស្រុកជីក្រែង។




៣.៦- ថ្ងៃទី១៣-១៨ ខែសីហា ឆ្នាំ២០១៨ បើកវគ្គបណ្តុះបណ្តាល PC&DFP ថ្មី DU#5 DU#6 DU#4 ស្តីពីការលើកកម្ពស់តួនាទី-ភារកិច្ច និងការយល់ដឹងពីមីន ព្រមទាំងជំនាញសម្របសម្រួលទំនាក់ទំនងសហគមន៍។





៣.៧- ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ សិក្ខាសាលាបុគ្គលិកMRE ចំនួន២៦នាក់ នៅDU#02បាត់ដំបងស្តីពីការត្រួតពិនិត្យការងារMREនិងកែលម្អការងារព្រមទាំងលើកផែនការសម្រាប់ឆ្នាំ២០១៨បន្តទៀត





៣.៨- ថ្ងៃទី៣១ ខែសីហា-ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ បើកវគ្គរំលឹកដល់ គណៈកម្មាធិការមីនស្ម័គ្រចិត្ត ១៧៧នាក់ ស្ថិតលើ៦ស្រុកមាន៖ រតនមណ្ឌល, គាស់ក្រឡ, រុក្ខគីរី, មោងឬស្សី ក្នុងខេត្តបាត់ដំបង និងស្រុកភ្នំក្រវ៉ាញ និងវាលវែង ក្នុងខេត្តពោធិសាត់។





៣.៩- ថ្ងៃទី១២-១៤ ខែមករា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានទាំងអស់ ចូលរួមរៀបចំតាំងពិព័រណ៍ កោះពេជ្រ រំលឹកខួបជ័យជម្នះ ៧មករា ទទួលបានជោគជ័យជាស្ថាពរ។




៣.១០- ថ្ងៃទី៦-៨ ខែមីនា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានចូលរៀបចំជ្រើសរើសបុគ្គលិកDFP ថ្មីសម្រាប់បំពេញការងារនៅខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។




៣.១១- ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានចូលរៀបចំពិព័រណ៍ សម្រាប់ទទួលប្រគល់សម្ភារៈជប៉ុន នៅខេត្តបាត់ដំបង។




៣.១២- ថ្ងៃទី១៦-១៧ ខែឧសភា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានទាំងអស់ចូលរួមរៀបចំតាំងពិព័រណ៍ នៅវិមានសន្តិភាពទទួលបានជោគជ័យជាស្ថាពរ។




៣.១៣- ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានអប់រំមីនចូលរួមរៀបក្នុងកម្មវិធីចុះអនុស្សរណៈ MRE ជាមួយអគ្គស្នងការនគរបាលជាតិ។




៣.១៤- ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋាន បានចូលរួមប្រជុំជាមួយអាជ្ញាធរមីន ស្តីពី កិច្ចប្រជុំក្រុមការងារបច្ចេកទេស អប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារ មីន/ សផស។




៣.១៥- ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានបានចូលរួមប្រជុំជាមួយជាមួយ នាយកដ្ឋានMRE របស់អាជ្ញាធរមីនកម្ពុជា។

៣.១៦- ថ្ងៃទី១៥ ខែធ្នូ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ បុគ្គលិកនាយកដ្ឋានទាំងអស់ បានចូលរួមរៀបចំតាំងពិព័រណ៍ នៅវិមានឈ្នះ ឈ្នះ ទទួលបានជោគជ័យជាស្ថាពរ។






## ៤-របាយការណ៍ អភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច

### ៤.១-សេចក្តីផ្តើម

គម្រោងអភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច ផ្តោតលើការយកចិត្តទុកដាក់ ជួយប្រជាជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ក្រោមជំនួយឥតចំណងពីរដ្ឋាភិបាលជប៉ុន ក្នុងគម្រោងកម្មវិធីសមាហរណកម្មបោសសំអាតមីន សង្គ្រោះជនរងគ្រោះដោយសារមីន ដំណាក់ការទី៣។

នេះជារបាយការណ៍ប្រចាំឆ្នាំទី២ (២០១៨) ស្តីពីសកម្មភាព និងលទ្ធផលសំរេចបាននៃគម្រោងអភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច ដោយផ្តោតទៅលើសកម្មភាពសកម្មភាពធំៗចំនួន២ សកម្មភាពទី១ ការងារវិស្វកម្មផ្តោតលើការស្តាបនាផ្លូវលំជនបទ និងផ្លូវដឹកផលិតផលកសិកម្មក្នុងតំបន់ដែលបានបោសសំអាតមីនរួច ក្នុងគម្រោងIMV-3។ សកម្មភាពទី២ សកម្មភាពបណ្តុះបណ្តាលជំនាញកសិកម្ម លើមុខវិជ្ជា៣ ពោលគឺៈទី១ ការបណ្តុះបណ្តាលមុខជំនាញផលិតកម្មដំណាំស្រូវ ទី២មុខជំនាញផលិតកម្ម ដំណាំដំឡូងមី និងទី៣ មុខជំនាញផលិតកម្មដំណាំកាហ្វេ ។ គម្រោងអភិវឌ្ឍន៍នេះ អនុវត្តក្នុងភូមិគោលដៅចំនួន៦ ឃុំគោលដៅចំនួន៤ និងស្រុកគោលដៅចំនួន២ (គឺស្រុករតនមណ្ឌល និងស្រុកសំឡូត) ខេត្តបាត់ដំបង ។

ទន្ទឹមនេះផងដែរមានគម្រោងមួយទៀតគឺ គម្រោងអភិវឌ្ឍន៍សហគមន៍ ជនបទរបស់អង្គការGood Earth Japan (GEJ) ក្នុងកិច្ចសហប្រតិបត្តិការជាដៃគូជាមួយអង្គភាព CMAC ។ គម្រោងនេះអនុវត្តក្នុង

ភូមិគោលដៅសរុបចំនួន១៨ភូមិ ឃុំគោលដៅចំនួន៣ (ឃុំស្ទឹង ឃុំឃ្លាំងមាស និងឃុំតាក្រាម) និងស្រុកគោលដៅចំនួន២ (ស្រុកបវេល និងស្រុកបាណន់)។

នេះជារបាយការណ៍ ស្តីពីសកម្មភាពរបស់គម្រោងអង្គការ Good Earth Japan (GEJ)ក្នុងឆ្នាំ២០១៨ ផ្តោតទៅលើសកម្មភាពធំៗចំនួន២ គឺទី១ សកម្មភាពអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធជារូបវន្ត ដូចជាសាងសង់អាគារសាលារៀន ស្រះទឹក ផ្លូវថ្នល់ និងទី២ សកម្មភាពបណ្តុះបណ្តាល ពមុខជំនាញកសិកម្ម ដូចជាការចិញ្ចឹមមាន់ស្រែធម្មជាតិ ផលិតកម្មដំណាំស្រូវ ផលិតកម្មដំណាំបន្លែ និងផលិតកម្មបណ្តុះផ្សិតចំបើង ។

## ៤.២-សកម្មភាពនិងលទ្ធផលសំរេចបាន

### ៤.២.១- គម្រោងអភិវឌ្ឍន៍ក្រោយបោសសំអាតមីនរួច

### ៤.២.១.១- សកម្មភាពនិងលទ្ធផលការងារវិស្វកម្ម

ការអនុវត្តន៍របស់ក្រុមការងារវិស្វកម្ម ស៊ីម៉ាក់ គឺអនុវត្តផ្អែកតាមគំនូរប្លង់ និងបទដ្ឋានបច្ចេកទេស សិក្សាដោយមន្ទីអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង។ មានជាអាទិ៖ ក្នុងឆ្នាំ២០១៨ គម្រោងអភិវឌ្ឍន៍ជំនួយពី រដ្ឋាភិបាលជប៉ុនបាននឹងកំពុងអនុវត្តផ្លូវលំជនបទ និងផ្លូវដឹកជញ្ជូនផលិតផលកសិកម្មចំនួន ៤ខ្សែ សរុបប្រវែង១៥គីឡូ១៧០ម៉ែត្រ និងស្ពានបេតុង១កន្លែងប្រវែងប្រវែង១១ម៉ែត្រ ។ សូមមើលលទ្ធផលសំរេចបានក្នុងតារាងទី១ ខាងក្រោមនេះ

តារាង ទី១

| ល.រ | ការអធិប្បាយ | Road Length (Metre) | ចំនួនសំណង់ | | | | ស្ថានភាព |
|---|---|---|---|---|---|---|---|
| | | | លូប្រអប់ | សំណង់បង្ហៀ | លូទោល | លូភ្លោះ | |
| 1 | ខ្សែផ្លូវដីទី១ | 4,250 | | | | | ដំណើរការ |
| 2 | ខ្សែផ្លូវដីទី២ | 2,370 | 1 | 2 | 1 | 5 | 80% |
| 3 | ខ្សែផ្លូវគ្រួសទី៣ | 4,200 | 2 | 2 | 3 | 3 | 90% |
| 4 | ខ្សែផ្លូវដីទី៤ | 3,000 | 1 | 1 | | 1 | ដំណើរការ |
| 5 | ខ្សែផ្លូវដីទី៥ | 1,350 | | | 2 | | 80% |
| 6 | ស្ពានបេតុង | | 1 | | | | ដំណើរការ |
| សរុប | | **8,550** | **4** | **3** | **5** | **4** | |

ផែនទី បង្ហាញទីតាំងគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធជនបទ គម្រោង សមាហរណកម្ម
បោសសំអាតមីន សម្រាប់ជនរងគ្រោះដោយសារមីន ដំណាក់កាលទី៣ ឆ្នាំទី២ (២០១៨)

**Map Indicate Location of Infrastructure Construction Under IMV-3 ( Year 2018 )**



### ៤.២.១.២-ការអធិប្បាយអំពីទីតាំងនៃខ្សែផ្លូវនីមួយៗ

**ខ្សែផ្លូវដីទី១**

ខ្សែផ្លូវនេះមានប្រវែង៤គីឡូ២៥០ម៉ែត្រ ស្ថិតនៅក្នុងភូមិតាគ្រក់ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។ មានប្រជាជនកំពុងរស់អមខាងផ្លូវនេះ ដែលអាចធ្វើចរាចរបានក្នុងតែរដូវប្រាំងប៉ុណ្ណោះ។ អាជ្ញាធរមូលដ្ឋានស្នើសុំ ស៊ីម៉ាក់ស្ថាបនាផ្លូវនេះ ដែលមានប្រជនទទួលចំនួន៤៣០គ្រួសារ និងមនុស្សរាយចំនួន១៦០០នាក់



**ខ្សែផ្លូវទី២**

ខ្សែផ្លូវនេះ ស្ថិតនៅក្នុងភូមិពេជ្រចង្វា ឃុំរស្មីសង្ហា ត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង។ ខ្សែផ្លូវនេះ ជាប្រភេទផ្លូវដី សំរាប់ដឹកជញ្ជូនផលិតផលកសិកម្ម ដែលមានប្រជានទទួលផលចំនួន ៩៧គ្រួសារ មនុស្សរាយចំនួន ៨១៧នាក់ ។



**ខ្សែផ្លូវទី៣**

ខ្សែផ្លូវនេះ ជាប្រភេទផ្លូវក្រាលគ្រួសធម្មជាតិ មានប្រវែង ៤គីឡូ២០០ម៉ែត្រ ដែកភ្ជាប់ពីចំណុចសាលាបឋមសិក្សា ក្នុងភូមិស្ទឹងតូច ទៅកាន់សាលាអនុវិទ្យាល័យវាលចម្បាំង ក្នុងឃុំកំពង់ល្ពៅ ស្រុកសំឡូត។ មានប្រជាជនទទួលផលចំនួន២៣០គ្រួសារ និងមនុស្សរាយចំនួន១១៥០នាក់។





**ខ្សែផ្លូវទី៤**

ខ្សែផ្លូវនេះជាប្រភេទផ្លូវដី មានប្រវែង៣គីឡូម៉ែត្រ ដែលជាចំណុចផ្ទុះមីនតោនម៉ាស៊ិនបោកស្រូវ ក្នុងឆ្នាំ២០១៥ ស្ថិតនៅក្នុងភូមិកំពង់ល្ពៅ ឃុំកំពង់ល្ពៅ ស្រុកសំឡូត។ អាជ្ញាធរមូលដ្ឋានស្នើសុំស៊ីម៉ាក់ជួយស្ថាបនាផ្លូវនេះ ដែលមានប្រជាជនទទួលផលចំនួន ៨៤គ្រួសារ មនុស្សរាយចំនួន៣០៦នាក់។



**ខ្សែផ្លូវទី៥**

ខ្សែផ្លូវនេះ ជាខ្សែផ្លូវចាស់ពីសម័យសង្គ្រាមប្រវែង ១គីឡូ៣៥០ម៉ែត្រ ភ្ជាប់ពីចំណុចចុងភូមិស្ទឹងតូច ទៅកាន់ចំណុចភូមិចម្លងរមាំងលើ ឃុំអូររំដួល ស្រុកសំឡូត ដែលមានប្រជាជនទទួលផលចំនួន ១៥០គ្រួសារ មនុស្សរាយចំនួន៧៥០នាក់។



ខ្សែផ្លូវនេះជួយគាំទ្រប្រតិបត្តិការក្រុមដោះមីន អាចធ្វើដំណើរទៅចំណុចភូមិចម្លង រមាំងលើ។

**ស្ពានបេតុង**



ផ្អែកតាមការស្នើសុំប្រប្រជាជន និងតម្រូវការកម្លាំងប្រតិបត្តិការបោសសំអាតមីនរបស់ស៊ីម៉ាក់ពិបាកធ្វើដំណើរឆ្លងកាត់ ហេតុដូចនេះ ត្រូវការស្ថាបនាស្ពានបេតុងជំនួសស្ពានឈើចាស់ទ្រុឌទ្រោមប្រវែង១១ម៉ែត្រ។

### ៤.២.១.៣-សកម្មភាពបណ្តុះបណ្តាលមុខវិជំនាញកសិកម្ម



ការបណ្តុះបណ្តាលជំនាញកសិកម្ម ផ្តោតលើសកម្មភាពចំនួន៣ គឺៈ មុខជំនាញផលិតកម្មដំណាំស្រូវ ផលិតកម្មដំណាំដំឡូងមី និងផលិតកម្ម ដំណាំកាហ្វេ ដោយមានគោលបំណង៣ខាងក្រោមៈ

- ផ្តល់ចំណេះដឹងមូលដ្ឋាន ជំនាញបទពិសោធ
- ផ្តល់ចំណេះដឹងពីរបៀបការគ្រប់គ្រងកសិដ្ឋាន
- ដឹកនាំអនុវត្តជាក់ជាក់ស្តែង រិះរកវិធីសាស្ត្រកាត់បន្ថយការចំណាយលើផលិតកម្ម។

### ៤.២.១.៤-ផលិតកម្មដំណាំស្រូវ



សរុបកសិករចំនួន៦៣នាក់ នៅក្នុងភូមិកំពង់ល្ពៅ ឃុំកំពង់ល្ពៅ ស្រុកសំឡូត បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើមុខជំនាញផលិតកម្មដំណាំស្រូវ ។ ក្នុងវគ្គបណ្តុះបណ្តាលនេះបែងចែកជា២ថ្នាក់ៈ ថ្នាក់ទី១មានកសិករចំនួន៣១នាក់ ហើយថ្នាក់ទី២មានកសិករចំនួន៣២នាក់។

**លទ្ធផលសំរេចបានលើផលិតកម្មដំណាំស្រូវ**

តារាងទី២ លទ្ធផលផលិតកម្មស្រូវ

| សាលាកសិករ | ចំនួនកសិករ | ទំហំផ្ទៃដី (m²) | ចំនួនពូជស្រូវផ្ការំដួល | ចំនួនផលស្រូវប្រមូល | តម្លៃស្រូវ (ប្រាក់រៀលខ្មែរ) | |
|---|---|---|---|---|---|---|
| | | | | | ស្រូវសើម | ស្រូវស្ងួត |
| សាលាទី១ | 29 | 46,400 | 450 | 22,691 | 0 | 1,000 |
| សាលាទី២ | 29 | 48,000 | 450 | 17,840 | | 1,000 |
| **សរុប** | **58** | **94,400** | **900** | **40,531** | **0** | **2,000** |

## ៤.២.១.៥-លទ្ធផលសំរេចបាននៃផលិតកម្មដំណាំដំឡូងមី

តារាងទី៣ ការវិភាគសេដ្ឋកិច្ចលើផលិតកម្មដំណាំស្រូវ

| សាលាកសិករ | សរុបតម្លៃផលិតកម្ម (ប្រាក់រៀល) (A) | ចំណូលទទួលបានពីផលិតកម្ម (ប្រាក់រៀល) | សរុបទិន្នផលប្រមូលបាន (គក) | តម្លៃស្រូវ (រៀល) | ប្រាក់ចំណេញ (ប្រាក់ខ្មែររៀល) (B - A = C) |
|---|---|---|---|---|---|
| | | | | តម្លៃស្រូវហាលស្ងួតបានលក់ | |
| សាលាទី ១ | 9,233,600 | 23,035,650 | 22,961 | 1,000 | 13,802,050 |
| សាលាទី ២ | 9,233,600 | 21,924,750 | 17,840 | 1,000 | 12,691,150 |
| សរុប | 18,467,200 | 44,960,400 | 40,801 | | 26,493,200 |

តារាងទី៤ លទ្ធផលផលិតកម្មដំណាំដំឡូងមី

| សាលាកសិករ | ចំនួនកសិករ | ចំនួនផ្ទៃដីដាំ (ម៉ែតការ៉េ) | ចំនួនពូជ (បាច់) | ចំនួនទិន្នផលប្រមូល | តម្លៃទីផ្សារ (គក/រៀល) | |
|---|---|---|---|---|---|---|
| | | | | | មើមស្រស់ | ដំឡូងស្ងួត |
| សាលាទី ១ | 29 | 21,000 | 300 | 83,931 | 250 | 0 |
| សាលាទី ២ | 28 | 19,600 | 290 | 83,652 | 250 | 0 |
| សាលាទី ៣ | 30 | 21,700 | 310 | 91,384 | 250 | 0 |
| **សរុបរួម** | **87** | **62,300** | **900** | **258,967** | **750** | **0** |

តារាងទី៥ វិភាគសេដ្ឋកិច្ចលើផលិតកម្មដំឡូងមី

| សាលាកសិករ | តម្លៃផលិតកម្ម (A) | ចំណូលទទួល (B) | ទិន្នផលប្រមូលបាន t (Kg) | តម្លៃលក់មើមដំឡូងមីនស្រស់ (គក/រៀល) | ប្រាក់ចំណេញ (B - A = C) |
|---|---|---|---|---|---|
| សាលាទី ១ | 8,078,385 | 21,344,348 | 83,931 | 250 | 13,265,963 |
| សាលាទី ២ | 7,799,820 | 21,122,074 | 83,652 | 250 | 13,322,254 |
| សាលាទី ៣ | 8,635,515 | 22,950,580 | 91,384 | 250 | 14,315,065 |
| សរុបរួម | 24,513,720 | 65,417,002 | 258,967 | | 40,903,282 |

## ៤.២.១.៦-ផលិតកម្មដំណាំកាហ្វេ

តារាង ម ខ បេ ម្ពួង បេ ផេ ផ បេ ត ក ម្ពុជ ណោ កាឈ្យ

| លេខ | ឈ្មោះកសិករ | ចំនួនកូនកាហ្វេផ្តល់ (ដើម) | ចំនួនផ្ទៃដីដាំសាកល្បង (ម៉ែត | ចំនួនពូជការហ្វេបានដាំ | ចំនួនពូជកាហ្វេសំរាប់ថ្នាល | ចំនួនកូនកាហ្វេ |
|---|---|---|---|---|---|---|
| 1 | Chhin Ratanak | 25 | 300 | 25 | 0.2 | 150 |
| 2 | Nai Jon | 25 | 300 | 25 | 0.2 | 150 |
| 3 | Pen Som Art | 25 | 300 | 25 | 0.2 | 150 |
| 4 | Bith Hoeun | 25 | 300 | 25 | 0.2 | 150 |
| 5 | Keal Poeun | 25 | 300 | 25 | 0.2 | 150 |
| 6 | Prak Nath | 25 | 300 | 25 | 0.2 | 150 |
| 7 | Eng SeavMao | 25 | 300 | 25 | 0.2 | 150 |
| 8 | Srey Lim | 25 | 300 | 25 | 0.2 | 150 |
| 9 | Reth Sarik | 25 | 300 | 25 | 0.2 | 150 |
| 10 | Chhin Socheath | 25 | 300 | 25 | 0.2 | 150 |
| 11 | Bun Sengyou | 25 | 300 | 25 | 0.2 | 150 |
| 12 | Im Thea | 25 | 300 | 25 | 0.2 | 150 |
| 13 | Moeuk Sopich | 25 | 300 | 25 | 0.2 | 150 |
| 14 | Tom Ny | 25 | 300 | 25 | 0.2 | 150 |
| 15 | Sem Run | 25 | 300 | 25 | 0.2 | 150 |
| 16 | Song Chheng | 25 | 300 | 25 | 0.2 | 150 |
| 17 | Eng Sim | 25 | 300 | 25 | 0.2 | 150 |
| 18 | Thak Lilin | 25 | 300 | 25 | 0.2 | 150 |
| 19 | Loum Sokunthea | 25 | 300 | 25 | 0.2 | 150 |
| 20 | Chhith Chanthoeur | 25 | 300 | 25 | 0.2 | 150 |
| 21 | Rim Khen | 25 | 300 | 25 | 0.2 | 150 |
| 22 | Eom | 25 | 300 | 25 | 0.2 | 150 |
| 23 | Bol Lim | 25 | 300 | 25 | 0.2 | 150 |
| 24 | Ny Neang | 25 | 300 | | 0.2 | 150 |
| 25 | Lay Vannara | 25 | 300 | 25 | 0.2 | 150 |
| **TOTAL 25 farmers** | | **625** | **7,500** | **600** | **5** | **3,750** |

## ៤.២.២ -គម្រោងអង្គការ Good Earth Japan (GEJ)



អង្គការGood Earth Japan (GEJ)បានអនុវត្តន៍ក្នុងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយស៊ីម៉ាក់ចាប់តាំងពីឆ្នាំ២០១៧ នៅក្នុង ៣ស្រុកគោលដៅចំនួន៤ ស្រុកបវេលបាណន់ រតនមណ្ឌលនិង គាស់ក្រឡ ក្នុងខេត្តបាត់ដំបង ។

តារាង ទិ ៧ ល ទ្ធផ ល ស័ ម្រ ច បាន ពិ ឆ្នាំ ២ ០ ០ ១ ដល់ ឆ្នាំ ២ ០ ១ ៨

| លេ ខ | ការ អ ធិ ប្បាយ | ឯ ក តា | [illegible] | | | | ស រុ ប | ចំ នួ ន អ្នក |
|---|---|---|---|---|---|---|---|---|
| | | | 2007-2010 | 2011-2014 | 2015-2017 | 2018 | | |
| **1** | **ហេ ដ្ឋារ ច ស ម្ព័ ន្ធ ប រិ ន្ត** | | | | | | | |
| 1.1. | ាគារ សាលាប ឋ ម សិ ក្សា | អាគារ | 2 | 2 | 1 | 1 | **6** | 2,397 |
| | | ប ន្ទប ផ្សៀ | 8 | 11 | 6 | 3 | **28** | |
| 1.2 | ផ្ទះ គ្រូ | ផ្ទះ | 0 | 2 | 3 | 0 | **5** | 32 |
| | | ប ន្ទប ស្នាក | 0 | 8 | 12 | 0 | **20** | |
| 1.3 | ផ្លូ វ ក្រាល គ្រួ ស | ម៉ែ ត្រ | 5,950 | 25,018 | 12,293 | 1,200 | **44,461** | 3,442 |
| 1.4 | ផ្លូ វ ដី | ម៉ែ ត្រ | 1,666 | 290 | 6,265 | 330 | **8,551** | 7,860 |
| 1.5 | អ ណ្ដូ ង ខ្ញួ ង ដាក់ ស្នប់ | អ ណ្ដូ ង | 6 | 0 | 0 | 0 | **6** | 620 |
| 1.6 | ស្រះ ទឹ ក | ស្រះ | 2 | 21 | 8 | 3 | **34** | 4,950 |
| **2** | **ប ណ្ដុះ ប ណ្ដាល ក សិ ក ម្ម** | | | | | | | |
| 2.1. | ការ ចិ ញ្ចឹ ម ន មាន់ | វ គ្គ | 460 | 960 | 480 | 285 | **2,185** | 2,251 |
| 2.2. | ផ លិ ត ក ម្មស្រូ វ | វ គ្គ | 656 | 960 | 540 | 60 | **2,216** | 2,216 |
| 2.3. | ស្ល ន ប ន្លែ | គ | | 960 | 360 | 160 | **1,480** | 1,590 |
| 2.4 | ផ លិ ត ក ម្មផ្សិ ត ចំ បើ ង | វ គ្គ | 608 | 860 | 1,200 | 125 | **2,793** | 2,893 |

សមិទ្ធផលដូចបានរៀបរាបជូនខាងលើនេះ គឺជាការរួមចំណែករបស់នាយកដ្ឋានអប់រំផ្សព្វផ្សាយជួយជនរងគ្រោះដោយសារមីន និងអភិវឌ្ឍន៍ក្រោយបោសសំអាតមីន ក្នុងកាត់បន្ថយអត្រាគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្រ្គាមនៅកម្ពុជា និងជួយអភិវឌ្ឍន៍ជីវភាពរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងតំបន់ទទួលរងការគំរាមកំហែងពីមីន និងគ្រាប់មិនទាន់ផ្ទុះ នៅក្នុងឆ្នាំ២០១៨។

ថ្ងៃព្រហស្បត៍ ១២កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨

**ប្រធាននាយកដ្ឋាន**